


# ប្រព័ន្ធធានាដោយមានការចូលរួម

## Participatory Guarantee System (PGS)

### អ្វីគឺជាប្រព័ន្ធធានាដោយមានការចូលរួម?

ប្រព័ន្ធធានាដោយមានការចូលរួមគឺជាប្រព័ន្ធផ្ទៀងផ្ទាត់ដើម្បីធានាឲ្យមានការយល់ព្រម ចំពោះការផលិតនូវផលិតផលស្របតាមស្តង់ដាសរីរាង្គ ដោយផ្អែកសំខាន់ទៅលើការចូលរួមយ៉ាងសកម្មរបស់កសិករ អ្នកប្រើប្រាស់, ទីប្រឹក្សាជនបទ, និងអាជ្ញាធរមូលដ្ឋាន។

### តើអ្វីជាគុណសម្បត្តិនៃការចូលរួមជាមួយប្រព័ន្ធធានាដោយមានការចូលរួម?

គុណសម្បត្តិការចូលរួមជាមួយប្រព័ន្ធធានាដោយមានការចូលរួមគឺ បន្ទាប់ពីមានការចូលរួមពីភាគីពាក់ព័ន្ធ PGS ជួយសម្រួលដល់ការចែករំលែកចំណេះដឹងក្នុងចំណោមកសិករ និងការកសាងទំនុកចិត្តជាមួយអតិថិជន។ តាមរយៈការធ្វើកសិកម្មសរីរាង្គ និងការចូលរួមជាមួយប្រព័ន្ធធានា កសិករនឹងមានឱកាសចូលរួមក្នុងប្រព័ន្ធទីផ្សារបានល្អប្រសើរ ដែលអាចធ្វើឲ្យអ្នកប្រើប្រាស់អាចមានប្រាក់ចំណូលសមរម្យ ខណៈពេលម្ហូបអាហារ ត្រូវបានធានាឲ្យមានសុវត្ថិភាពល្អ តាមរយៈការគោរពតាមគោលការណ៍មូលដ្ឋានគ្រឹះរបស់កសិកម្មសរីរាង្គពីអ្នកផលិត។

### កសិករ

- ការផ្លាស់ប្តូរចំណេះដឹង
- ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់
- ទទួលបានវិញ្ញាបនបត្រ PGS បញ្ជាក់ពីគុណភាពសរីរាង្គ
- ភាពច្បាស់លាស់នៃបទដ្ឋានក្នុងការផលិតដ៏ត្រឹមត្រូវ
- បរិស្ថានកាន់តែល្អប្រសើរ ។



### ទីផ្សារ

- ឱកាសទីផ្សារក្នុងស្រុក
- បង្កើនសេដ្ឋកិច្ចក្នុងតំបន់
- ភ្ជាប់ទំនាក់ទំនងជិតស្និទ្ធរវាងអ្នកផលិត និងអ្នកប្រើប្រាស់។




### អតិថិជន

- ទទួលបានអាហារដែលមានសុវត្ថិភាព
- ការប្រើប្រាស់ដោយមានការទទួលខុសត្រូវចំពោះបរិស្ថាន និងសង្គម
- អ្នកប្រើប្រាស់អាចមកទស្សនៈកិច្ចជាមួយអ្នកផលិតដើម្បីបញ្ជាក់ពីភាពជឿជាក់គ្នាទៅវិញទៅមក ។




Food and Agriculture Organization of the United Nations

CEDAC

រៀបចំដោយ:
មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)
គាំទ្រដោយ:
អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)

ស្លាកសញ្ញា PGS មួយចំនួននៅក្នុងប្រទេសកម្ពុជា

I7257KM/1/05.17
©FAO 2017